**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ:៣៥៨
ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០២
<u>**សាលដីកា**</u>
លេខ:១០៣
ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម **ឃឹម ប៉ុណ្ណ** ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក **ស៊ិន ឌឹម** ជាចៅក្រម
៣-លោក **ជីវ កេង** ជាចៅក្រម
៤-លោក **សោម សិរីវឌ្ឍ** ជាចៅក្រមរបាយការណ៍
៥-លោក **ម៉ុង មុន្នីចរិយា** ជាចៅក្រម

<u>**ក្រឡាបញ្ជី**</u>

-លោក **អ៊ូ សុផុន**

<u>**តំណាងមហាអយ្យការ**</u>

-ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ១០៤(ឈ) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០២នៃសំណុំរឿងរដ្ឋប្បវេណីលេខ៥៩៣ចុះថ្ងៃទី១០ខែកញ្ញាឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍រវាងៈ

ដើមចោទឈ្មោះសឿន ម៉ា (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៤០ឆ្នាំ ជាតិខ្មែរមុខរបរធ្វើស្រែ ទីលំនៅភូមិគីឡូម៉ែត៤ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះដា សឿន (ស) ម្តាយឈ្មោះឆេង មាច(រ) ប្រពន្ធឈ្មោះចាន់ យឿង ។

មានមេធាវីលោក ហែម វុន និងលោក ទូត លុច ។

ចុងចម្លើយឈ្មោះពុទ្ធិ ង៉ុច (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៣៨ឆ្នាំជាតិខ្មែរមុខរបរ ប៉ូលីស ទីលំនៅគីឡូម៉ែត៤ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះពុទ្ធិ ថានី(រ)ម្តាយឈ្មោះចាំង លាប (ស) ប្រពន្ធឈ្មោះប៉ែន សោភា ។

<u>**កម្មវត្ថុបណ្តឹង:**</u> ប្តឹងទាមទារដីទំហំ ៣ ហិកតា ។

បានឃើញបណ្តឹងសាទុក្ខលេខ២៧៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ របស់ឈ្មោះចាន់ យឿង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១០៤(ឈ) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៥៨ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០២របស់តុលាការ កំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៩-០៦-២០០០ របស់ដើមចោទឈ្មោះសឿន ម៉ា ប្តឹងទាមទារសុំសិទ្ធិគ្រប់គ្រងដីស្រែទំហំ០៣ហិកតា ចំណុចគោស្បែង ភូមិគីឡូម៉ែតលេខ៤ ឃុំប៉ោយប៉ែតពីឈ្មោះពុទ្ធិ ង៉ុប ដោយអាងហេតុថា ដីស្រែទំនាស់ចំនួន០៣ហិកតានេះ ខ្លួនបានកាន់កាប់ និងបង្កបង្កើនផលស្រូវជារៀងរាល់ឆ្នាំ ។ លុះមកដល់ក្នុងកំឡុងខែឧសភា ឆ្នាំ១៩៩៩ ស្រាប់តែឈ្មោះពុទ្ធិ ង៉ុប បានទៅភ្ជួររាស់លើដីស្រែនេះ ធ្វើឱ្យខូចខាតផលដំណាំរបស់ខ្លួនដែលកំពុងលូតលាស់អស់ចំនួន០១ហិកតា និងបានអះអាងថា ដីស្រែទាំង០៣ហិកតានេះ គាត់បានទិញពីឈ្មោះគិល ទឹម អតីតប្រធានភូមិគីឡូម៉ែតលេខ៤ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដោយលបលួច ធ្វើប្លង់កម្មសិទ្ធិក្លែងក្លាយដើម្បីលក់ដីស្រែនេះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៥៨ ចុះថ្ងៃទី០៣ខែសីហាឆ្នាំ២០០១ របស់តុលាការខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៩-០៦-២០០០ របស់ឈ្មោះសឿន ម៉ា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ប្រគល់ដីទំនាស់ ដែលមានព្រំប្រទល់ខាងជើងទល់នឹងដីរបស់អន ធន ខាងត្បូងទល់នឹងឈ្មោះឈួន ហៃ ខាងលិច និងខាងកើត ទល់នឹងដីរបស់សឿន ម៉ា ឱ្យទៅឈ្មោះពុទ្ធិ ង៉ុប កាន់កាប់ជាកម្មសិទ្ធិកាលណាសាលក្រមចូលជាស្ថាពរ ។

៣-បង្គាប់ឱ្យឈ្មោះសឿន ម៉ា បង់ប្រាក់ប្រដាប់ក្តី និងពន្ធសមាមាត្រ១%នៃតំលៃដីទំនាស់ កាលណាសាលក្រមចូលជាស្ថាពរ ។

សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូភាគី បើកផ្លូវប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០១ របស់ឈ្មោះចាន់ យឿង ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៥៨ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០១ របស់តុលាការ ខេត្តបន្ទាយមានជ័យ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១០៤(ឈ) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០១ របស់ឈ្មោះចាន់ យឿង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៥៨ ចុះថ្ងៃទី០៣ សីហា ២០០១ របស់ តុលាការខេត្តបន្ទាយមានជ័យ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ ដែលចុងចម្លើយ បានបង់ទុករួចហើយ គឺពន្ធហ្នឹង និងពន្ធចុះបញ្ជីក្ដីចំនួន២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០៛ ចំណាយលើការប្រគល់ដីកាកោះចំនួន៥.០០០៛ និងអាជ្ញាធរតុលាការចំនួន៥០០០៛ ។

៤-សាលដីកានេះដំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខតំណាងដើមចោទ និងចុងចម្លើយ។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ២៧៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ របស់ឈ្មោះចាន់ យឿង ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១០៤(ឈ) ចុះថ្ងៃទី២៥ ខែមិថុនាឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៣ របស់ឈ្មោះធូ ហុក តំណាងឱ្យប្រពន្ធរបស់ដើមចោទឈ្មោះចាន់ យឿង ។

បានឃើញសារណាតបចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៣ របស់ឈ្មោះពុទ្ធិ ង៉ុប ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា : រឿងនេះតុលាការថ្នាក់ក្រោមពុំទាន់បានពិចារណាលើកិច្ចសន្យាទិញ-លក់ និងចុះអង្កេតនៅឡើយទេ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះចាន់ យឿង នាពេលសវនាការថា : ដីទំនាស់នេះខ្លួនបានកាន់កាប់បង្កបង្កើនផលតាំងពីឆ្នាំ១៩៩១ មក ។ នៅឆ្នាំ១៩៩៤ ឈ្មោះតឹល ទឹម មកសុំដូរដីជាមួយខ្លួន។ ក្នុងការដោះដូរនោះ គឺឈ្មោះតឹល ទឹម យកក្រដាសសៀវភៅមកសរសេរកិច្ចសន្យាដោយផ្ទាល់ដៃតែម្ដង ។ម្យ៉ាងទៀត តាមគំនូសប្លង់ស្រុកអូរជ្រៅពុំបានកំណត់ព្រំច្បាស់លាស់ទេ ហើយមានលក្ខណៈផ្ទុយគ្នាទៀត ។

បានស្ដាប់ចម្លើយរបស់ឈ្មោះពុទ្ធិ ង៉ុប នាពេលសវនាការថា ដីស្រែទំនាស់០៣ហិកតានេះបានទិញពីឈ្មោះតឹល ទឹម ដោយមានសាក្សីសំអាងច្បាស់លាស់ដូចជា នូ សារ៉ន ទូច សឿន,ឈួន ហៃ ស៊ុន ប៊ុនថន ជា ចំរើន ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោកហែម វុន ជាមេធាវីការពារឱ្យដើមចោទនាពេលសវនាការថា៖ រឿងដីទំនាស់ទំហំ២០០ម គុណ ១៥០ម នេះ គឺធ្លាប់មានបញ្ហាពីការក្លែងលិខិត របស់ឌុទ្ធកាល័យសម្ដេច ជា ស៊ីម រហូតមានការចាប់ឈ្មោះតឹល ទឹម ដាក់គុក ។ ដូច្នេះការណ៍ដែលតុលាការសម្រេចប្រគល់ដី ដែលគេបានដឹងថា ឈ្មោះតឹល ទឹម បានក្លែងយកមកនោះទៅជា ដីរបស់តឹល ទឹម វិញគឺជាការបំពានដោយចេតនាទៅលើគតិច្បាប់ ។

សុំឱ្យតុលាការបដិសេធសាលដីកាសាលាឧទ្ធរណ៍ចោល និងសុំឱ្យចុះអង្កេតឡើងវិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ទួត លុច មេធាវីការពារឲ្យដើមចោទ នាពេលសវនាការថាៈ ក្នុងការសម្រេចសេចក្តីរបស់តុលាការកន្លងមក ត្រូវបានសម្រេចយកទាំងដី ដែលភាគីកូនក្តីខ្លួនបានដូរជាមួយលោកថាច់ កុសល ។

កន្លងមក តុលាការពុំបានកោះហៅឈ្មោះថាច់ កុសល មកឆ្លើយបំភ្លឺ ដើម្បីជាប្រយោជន៍ ក្នុងរឿងក្តីនេះទេ ។

សុំឯកឧត្តមប្រធានក្រុមប្រឹក្សាជំនុំជំរះបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោល ហើយសុំឱ្យចុះអង្កេតឱ្យបានច្បាស់លាស់ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៧៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ របស់ឈ្មោះចាន់ យឿង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានដោយយោងតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការណ៍ដែលសាលាឧទ្ធរណ៍ ក៏ដូចជាតុលាការខេត្តបន្ទាយមានជ័យដែរ ដែលបានសម្រេចប្រគល់ដីទំនាស់ឱ្យទៅឈ្មោះពុទ្ធិ ង៉ុប កាន់កាប់ជាកម្មសិទ្ធិ ដោយអាងហេតុថា ចុងចម្លើយ និងសាក្សីថា លោកពុទ្ធិ ង៉ុប បានទិញដីនេះពីឈ្មោះតុល ទឹម ដែលបានរុករាន និងបង្កបង្កើនផលតាំងពីឆ្នាំ ១៩៩១ រហូតដល់ឆ្នាំ១៩៩៩ ទើបលក់ឱ្យលោកពុទ្ធិ ង៉ុបនោះពុំទាន់មានសំអាងគ្រប់គ្រាន់ទេ ពីព្រោះថាៈ

- តុលាការខេត្តបន្ទាយមានជ័យ និងសាលាឧទ្ធរណ៍កំណត់ព្រំប្រទល់ដីទំនាស់ តាមចម្លើយសាក្សីចុងចម្លើយថា ខាងជើងទល់នឹងដីឈ្មោះអន ឆាន ខាងលិច និងខាងកើតទល់ នឹងដីឈ្មោះសឿន ម៉ា ។ ប៉ុន្តែ តាមគំនូសប្លង់ទីតាំងដីទំនាស់ចុះថ្ងៃទី១៧-០៥-២០០២ របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកអូរជ្រៅ និងតាមចម្លើយរបស់ដើមចោទ និងចុងចម្លើយពេលសវនាការនេះបញ្ជាក់ថា ព្រំប្រទល់ខាងជើង គឺទល់នឹងចាន់ យឿង និងហ៊ិន ឆង ពុំមានឈ្មោះអន ឆាន ទេ ហើយព្រំប្រទល់ខាងលិច គឺទល់នឹងឈ្មោះគង់ សុផាត និងឈ្មោះមួង វិបុល ពុំមានឈ្មោះសឿន ម៉ា ទេ ។

-តាមគំនូសប្លង់ចុះថ្ងៃទី១៧-០៥-២០០២ និងចុះថ្ងៃទី២៤-០១-២០០២ របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកអូរជ្រៅ ពុំដូចគ្នាទេ ។

-យល់ឃើញថា ការណ៍ដែលសាលាឧទ្ធរណ៍យល់ឃើញថាលិខិតដូរដីចុះថ្ងៃ២៥-០៣-១៩៩៤ រវាងដើមចោទ និងលោកតុល ទឹម ពុំមានច្បាប់ដើមនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះដើមចោទបាន

បញ្ជាក់ថា លិខិតច្បាប់ដើមនេះ បានបង្ហាញសាលាឧទ្ធរណ៍រួចហើយ ហើយនៅពេលសវនាការនេះ ដើមចោទក៏បានបង្ហាញតុលាការកំពូលដែរ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១០៤(ឈ)ចុះថ្ងៃទី២៥ខែមិថុនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទម្រង់ទាំងគតិច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ២៧៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ របស់ឈ្មោះចាន់ យឿង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ១០៤(ឈ) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣៥៨ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០២ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៥.០០០៛ ដែលដើមចោទបានបង់ទុកនៅតុលាការកំពូលគឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប ១៩.០០០៛ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤ ។